11007

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍ស្តីពី

# ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្ខេបដំបូង

លើគំរោងសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែមាស នៅតំបន់ភ្នំដែក ឃុំរមទម
ស្រុករវៀង ខេត្តព្រះវិហារ នៅលើផ្ទៃដីសរុប ១០០ហិកតា


## ក្រុមហ៊ុន ដែលខុម (កម្ពុជា) ភីធីអ៊ី អិលធីឌី
## DELCOM (KAMPUCHEA) PTE. LTD.

ទីស្នាក់ការក្រុមហ៊ុនៈ No.7 ផ្លូវលេខ ៥៦៤ ក្រុមទី៤៤ ភូមិ៧ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ ០១៦ ៨១៤ ៧៣១/០៨០ ៧៨១ ៧៨១

អ៊ីម៉ែលៈ keith.nthem@yahoo.com
tvnhem@yahoo.com
touchmengtek@gmail.com


ខែ តុលា ឆ្នាំ ២០១១

# ជំពូកទី៧

# ផែនការគ្រប់គ្រងបរិស្ថាន

## ៧.១ សេចក្តីផ្តើម

**១៩៥.** យោងតាមវិធានការគ្រប់គ្រងដូចមាននៅក្នុងរបាយការណ៍វាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងផែនការគ្រប់គ្រងបរិស្ថាន សំរាប់គំរោងស្រាវជ្រាវនឹងធ្វើអាជីវកម្មរ៉ែមាស ម្ចាស់គំរោងជាអ្នកទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រងបរិស្ថានរបស់គំរោងនេះ ចំណែកឯក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរខេត្ត ជាអ្នកពិនិត្យការអនុវត្តន៍របស់ម្ចាស់គំរោង។

**១៩៦.** យោងលើកំរិតនៃផលប៉ះពាល់បង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍ បង្ហាញថាគំរោងនេះតម្រូវឱ្យមានការចូលរួមពីស្ថាប័ន និងការត្រួតពិនិត្យបរិស្ថានច្រើន ព្រោះហេតុប៉ះពាល់អវិជ្ជមានអាចមានសភាពធ្ងន់ធ្ងរ ប្រសិនបើម្ចាស់គំរោង មិនយកចិត្តទុកដាក់ចំពោះបញ្ហាបរិស្ថាន។ ដូច្នេះ ក្រៅពីអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator) និងស្ថាប័នជំនាញ (មានក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) គម្រោងនេះចាំបាច់តម្រូវឱ្យមានស្ថាប័នត្រួតពិនិត្យឯករាជ្យ (Independent Monitoring Organization) ដើម្បីត្រួតពិនិត្យការអនុវត្តន៍។ ក្រុមហ៊ុនខ្លួនឯងមានតួនាទីទទួលខុសត្រូវស្នូលក្នុងការគ្រប់គ្រងបរិស្ថាន របស់គំរោងដោយផ្អែកលើវិធានការណ៍គ្រប់គ្រងបរិស្ថានដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន របស់របាយការណ៍ IESIA។ ក្នុងបរិបទនេះ ដើម្បីធានាបានថា **ក្រុមហ៊ុន** DELCOM (KAMPUCHEA) PTE.LTD. ប្រតិបត្តិតាមវិធានការណ៍នៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ដូចកំណត់នៅក្នុងតារាងទី ៧-១ និង៧-៣ បានត្រឹមត្រូវនោះក្រសួងបរិស្ថាន (នាយកដ្ឋាន EIA) និងក្រុមការងារចំរុះអន្តរៈក្រសួងត្រូវចុះពិនិត្យ និងវាយតំលៃដំណើរប្រតិបត្តិរបស់ក្រុមហ៊ុន ទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងតារាង ៧-៣ ដោយផ្ទាល់។

## ៧.២ សមាសភាពនៃក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការណ៍កិច្ចការពារបរិស្ថាន

**១៩៧.** សមាសភាពនៃក្រុមត្រួតពិនិត្យនេះ មានសមាជិកចំរុះមកពីស្ថាប័នជំនាញពាក់ពន្ធ័ដូចតទៅ:

១. មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាន

២. មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន

៣. មន្ត្រីជំនាញតំណាងឱ្យមន្ទីរបរិស្ថាន ខេត្តព្រះវិហារ

៤. មន្ត្រីជំនាញតំណាងឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៥. អ្នកតំណាងឱ្យក្រុមហ៊ុន

៦. អភិបាលខេត្តនិងមន្ទីរជំនាញខេត្តព្រះវិហារ

៧. ប្រជាជនមូលដ្ឋានក្នុងតំបន់គំរោង

**បញ្ជាក់:** សមាសភាពមន្ត្រីទាំងអស់នេះ នឹងត្រូវផ្តល់តួនាទី និងមុខងារក្រោមការចង្អុរបង្ហាញពីក្រសួងបរិស្ថាន ។

## ៧.៣ ផែនការគ្រប់គ្រងបរិស្ថាន

### ៧.៣.១ វិធានការការពារបរិស្ថាន

**១៥៨.** យោងតាមអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង យោងតាមលទ្ធផលនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គំរោង ដូចបានរៀបរាប់នៅក្នុងជំពូកខាងដើមនេះ ម្ចាស់គំរោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួន សំរាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះដោយប្រសិទ្ធិភាព ស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថាន ព្រមទាំងធានាឱ្យមានចីរភាពនៃគំរោងអភិវឌ្ឍន៍ ដែលក្នុងនោះម្ចាស់គំរោងនឹង :

-រៀបចំក្រុម ឬផ្នែកបរិស្ថានសំរាប់ការអនុវត្តន៏ផែនការនេះ

-រៀបចំផែនការសកម្មភាពការងារឱ្យច្បាស់លាស់ ក្នុងកិច្ចការការពារបរិស្ថាន

-បំពាក់ឧបករណ៏ការពារសុខភាព, គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស

-ការពារគ្រោះថ្នាក់ដោយយថាហេតុពីសកម្មភាពគំរោងទៅលើធនធានធម្មជាតិ និងសង្គម

-ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំង-បច្ចេកទេស និង ទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតំរូវអោយធ្វើ ។

### ៧.៣.២ កម្មវិធីបំពាក់បំប៉ន

**១៥៩.** កម្មវិធីបំពាក់បំប៉នក៏ជាកត្តាសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលគំរោងត្រូវយកចិត្តទុកដាក់ ដើម្បីអនុវត្តផែនការមេរបស់គំរោងបានជោគជ័យ ។ ដើម្បីធ្វើឱ្យគំរោងវិនិយោគនេះមានការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាពនោះ ចាំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំពេញការងារឱ្យបានរីកចំរើន ទាំងការងារបច្ចេកទេស និងការងារបរិស្ថាន។ ដូច្នេះ ម្ចាស់គំរោងនឹងរៀបចំឱ្យមានវគ្គអប់រំបំពាក់បំប៉នដល់បុគ្គលិក និងកម្មករមានដូចជា :

-ចំណេះដឹងបច្ចេកទេសនៃការជីក-លុងរណ្តៅរ៉ែ ការបញ្ជាគ្រឿងចក្រ និងឧបករណ៏គ្រប់ប្រភេទក្នុងពេលដំណើរការអាជីវកម្ម

-ចំណេះដឹងពីការការពារសុវត្ថិភាព ពេលកំពុងបំពេញការងាររបស់គំរោង

-អប់រំដល់កម្មករឱ្យបំពាក់ឧបករណ៍ការពារសុខភាពពេលកំពុងធ្វើការងារ

-បំពាក់បំប៉ន និង ផ្សព្វផ្សាយពីជំនាញបច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ

-អប់រំ និងផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃឈើ និងសត្វព្រៃ

-អប់រំ និងផ្សព្វផ្សាយពីវិធីសាស្ត្រការពារជំងឺរាតត្បាតផ្សេងៗ ដែលអាចមាននៅក្នុងតំបន់គំរោង

-ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំ វិធីសាស្ត្រការពារសុខភាព-សុវត្ថិភាព

-ត្រៀមថវិការបំរុងទុក សំរាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន ។

## ៧.៣.៣ កម្មវិធីត្រួតពិនិត្យបរិស្ថាន

**១៦០.** កម្មវិធីត្រួតពិនិត្យបរិស្ថាននេះ មានបំណងសំខាន់ គឺដើម្បីកំណត់ទំហំ និងប្រៀបធៀបឱ្យដឹងថាៈ រវាង ហេតុប៉ះពាល់បរិស្ថាន វិធានការកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានដែលបានសិក្សាទាំងនោះ ហើយនឹងលទ្ធផលនៃការងារត្រួតពិនិត្យបរិស្ថាននៅក្នុងតំបន់គំរោងជាក់ស្តែង នៅគ្រប់ដំណាក់កាលរបស់គំរោង តើវាអាចធាបាននូវចីរភាពបរិស្ថានដែរឬទេ?

**១៦១.** ការត្រួតពិនិត្យបញ្ហាបរិស្ថាននឹងត្រូវអនុវត្តដោយម្ចាស់គំរោងនៅគ្រប់ដំណាក់កាលនៃគំរោង ហើយលទ្ធផលនៃការត្រួតពិនិត្យនេះ ក្រុមហ៊ុននឹងធ្វើរបាយការណ៍ផ្ញើរជូនក្រសួងបរិស្ថានរាល់ ០៣ ខែ/ម្តង ដើម្បីវាយតំលៃពីសកម្មភាពគំរោង ហើយនឹងចុះអង្កេត តាមដាន សំរាប់កែលំអក្នុងកិច្ចដំណើរការរបស់គំរោង ទៅតាមបទពិសោធន៍-បច្ចេកទេស និងបញ្ចៀសបាននូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរឱ្យដល់កំរិតអប្ប - បរិមា។ ចំណែកហេតុប៉ះពាល់វិជ្ជមានក្រុមហ៊ុននឹងខិតខំធ្វើ ការកែច្នៃឱ្យបានប្រសើរថែមទៀត។ ក្នុងករណីពិសេសណាមួយ ដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម ដោយសារសកម្មភាពគំរោង ក្រុមហ៊ុននឹងអញ្ជើញមន្ត្រីជំនាញនៃក្រសួងបរិស្ថាននិងក្រសួងពាក់ព័ន្ធ ដើម្បីចុះអង្កេត និងធ្វើការកែលំអ ។

**១៦២.** កម្មវិធីត្រួតពិនិត្យបញ្ហាបរិស្ថានសំខាន់ៗ នៅគ្រប់ដំណាក់កាលរបស់គំរោងនេះម្ចាស់គំរោងនឹងធ្វើការត្រួតពិនិត្យលើបញ្ហាបរិស្ថានសំខាន់ៗមួយចំនួនមាន :

### ១.ដំណាក់កាលមុនប្រតិបត្តិគំរោង

**១៦៣.** នៅដំណាក់កាលនេះ ក្រុមការងារនឹងធ្វើការត្រួតពិនិត្យទៅលើធនធានធម្មជាតិសំខាន់ៗមួយចំនួន ដែល

នឹងអាចទទួលរងនូវឥទ្ធិពលអាក្រក់ពីសកម្មភាពគំរោង មានដូចជាៈ សណ្ឋានដី គុណភាពខ្យល់ ប្រព័ន្ធជលសាស្រ្ត សំលេង-រំញ័រ ព្រៃឈើ សត្វព្រៃ មុខរបរ និងការរស់នៅរបស់សហគមន៍ពាក់ព័ន្ធ ។

## ២. ដំណាក់កាលប្រតិបត្តិគំរោង

**១៦៤.** ការងារសំរាប់ការត្រួតពិនិត្យបរិស្ថាននៅក្នុងដំណាក់កាលនេះ ជាការងារសំខាន់ជាងដំណាក់កាលផ្សេងៗទៀត ដែលសកម្មភាពអាចបង្កអោយប៉ះពាល់ដល់ធនធានធម្មជាតិសំខាន់ៗ ក្នុងតំបន់នោះក្នុងរយៈពេលវែង ។ ដូចនេះ ទិសដៅសំខាន់នៃការត្រួតពិនិត្យទៅលើធនធានសំខាន់ៗមានដូចជាៈ សណ្ឋានដី គុណភាពដី គុណភាពទឹក ប្រព័ន្ធជលសាស្រ្ត គុណភាពខ្យល់ សត្វព្រៃ ព្រៃឈើ សំលេង-រំញ័រ ជីវៈចំរុះក្នុងទឹក ការគ្រប់គ្រងសំណល់រឹង-រាវ ហេដ្ឋារចនាសម្ព័ន្ធ ទំនៀមទំលាប់ ប្រពៃណី ការគ្រប់គ្រងឧបករណ៍-សម្ភារៈ និងសុខភាពសាធារណៈ ។ល ។

## ៣. ដំណាក់កាលបញ្ចប់គំរោង

**១៦៥.** នៅដំណាក់កាលនេះ ក្រុមការងារនឹងត្រួតពិនិត្យលើធនធានធម្មជាតិសំខាន់ៗមួយចំនួនដូចជាៈ ការប្រើប្រាស់ដីគុណភាពទឹក-ដី ជីវចំរុះក្នុងទឹក មុខរបរនិងការរស់នៅ និងហេដ្ឋរចនាសម្ព័ន្ធ ។

## ៧.៣.៤ ថវិកាសំរាប់ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន

**១៦៦.** តំលៃដែលគ្រោងសម្រាប់ឧបត្ថម្ភ តាមដានពិនិត្យវាយតំលៃ ពង្រឹងសមត្ថភាពប៉ាន់ស្មានជាអស់ ៨២៩.៤២០ដុល្លា (ប៉ែតសិបពីរម៉ឺនប្រាំបួនពាន់ប្រាំមួយរយម្ភៃ) មួយឆ្នាំសម្រាប់ការដ្ឋាននិមួយៗក្នុងនោះមានៈ (១) ការអនុវត្តន៍នូវផែនការគ្រប់គ្រងបរិស្ថាន ចំនួន៣១៦.១០០ដុល្លា (២) ការតាមដានពិនិត្យវាយតំលៃចំនួន១០.៣២០ដុល្លា (៣) ការពង្រឹងសមត្ថភាពចំនួន៣.០០០ដុល្លា និង (៤) ចំពោះគំរោងថវិកា ដែលគ្រោងសំរាប់ការជួសជុល នឹងកែប្រែបរិស្ថាន នៅក្នុងអាយុកាលនៃការធ្វើអាជីវកម្មរ៉ែត្រូវបានប៉ាន់ស្មានថាអស់ចំនួន ៥០០.០០០ដុល្លា។ ចំណែកឯថវិកាបម្រុងសម្រាប់បុគ្គលិក/កម្មករ ដែលទទួលគ្រោះថ្នាក់ដោយចៃដន្យ ដោយសារសកម្មភាព គំរោងនៅក្នុងរយៈពេលនៃប្រតិបត្តិការ មិនបានដាក់បញ្ចូលទៅក្នុងតារាងតំលៃប៉ាន់ស្មានសំរាប់ការអនុវត្តន៍ និងតាមដានពិនិត្យវាយតំលៃនោះទេ។ តែក្រុមហ៊ុនត្រូវមានថវិកាបំរុងគ្រប់គ្រាន់សំរាប់គំរោងថវិកានេះ នៅក្នុងករណីនៃឧបទ្ទវហេតុដែលអាចកើតមានឡើងជាយថាហេតុ (មើលតារាង ៧-២) ។

**១៦៧.** បច្ចុប្បន្នសមត្ថភាពរបស់ម្ចាស់គំរោងក្នុងការអនុវត្តន៍នូវ EMP នៅមានកំណត់។ ដូច្នេះ ម្ចាស់គំរោងត្រូវជួលបុគ្គលិក១នាក់ ដើម្បីត្រួតពិនិត្យតាមដានវាយតំលៃនូវដំណើរប្រតិបត្តិការអាជីវកម្មជាប្រចាំ។ តារាង ៧-២ ខាងក្រោមនេះបង្ហាញពីតំលៃប៉ាន់ស្មានសំរាប់ការអនុវត្តន៍នូវ EMP និងការត្រួតពិនិត្យតាមដានវាយតំលៃនូវដំណើរប្រតិបត្តិការរបស់គំរោងស្រាវជ្រាវនឹងធ្វើអាជីវកម្មរ៉ែមាស។

**តារាង ៧-១: តំលៃប៉ាន់ស្មានសម្រាប់ការអនុវត្តន៍ EMP និងការត្រួតពិនិត្យតាមដាន**

| សកម្មភាព | សកម្មភាពដែលត្រូវអនុវត្ត | ចំនួន/ រយៈពេល | តំលៃជា ឯកតា ($) | តំលៃសរុប ($) |
|---|---|---|---|---|
| ការអនុវត្តន៍ វិធានការណ៍ កាត់បន្ថយ | pH Meter (អតិបរិមាប្រើបាន២ឆ្នាំ) | ២សំរាប់ | ៤៥០ | ៩០០/២ |
| | តំលៃសម្រាប់ពិនិត្យរកលោហៈធុនធ្ងន់ COD និង BOD (២ខែម្តង) ប៉ាន់ស្មានសរុប | សរុប | ប៉ាន់ស្មានសរុប | ៧.២០០/៦ |
| | បណ្តុះបណ្តាលបុគ្គលិកពីសុខភាពការងារ និង ផែនការសុវត្ថិភាព | ៣ថ្ងៃ/៦ខែ | ៥០០ | ៣០០០ |
| | ការរៀបចំប្រព័ន្ធធ្វើអោយទឹករង | សរុប/ការដ្ឋាន | ៣៥.០០០ | ៣៥០០០ |
| | ការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់ | សរុប/ការដ្ឋាន | ១២០.០០០ | ១២០០០០ |
| | ការធ្វើប្រព្រឹត្តកម្មទឹក (សរុប/ឆ្នាំ) | សរុប/ការដ្ឋាន | ១៥០.០០០ | ១៥០០០០ |
| | ការផ្តល់ពត៌មានអំពីសុខភាពសាធារណៈ | ០ | ០ | ០,០០ |
| | **សរុប (១)** | | | **៣១៦.១០០** |
| ការត្រួតពិនិត្យ | ជួលបុគ្គលិកអចិន្ត្រៃយ៍ចំនួន១នាក់ដើម្បីបណ្តុះអោយធ្វើជា Local Environmental Coordinator | ០១/ខែ | ១/៣៥០/ខែ | ៤២០០ |
| | មន្ត្រីសមត្ថកិច្ចស្រុក និងខេត្ត | ២/២ថ្ងៃ/ខែ | ១/៣០/ថ្ងៃ | ១៤៤០ |
| | ក្រុមប្រឹក្សាឃុំ (២នាក់) | ២/១ថ្ងៃ/ខែ | ១/១៥/ថ្ងៃ | ៣៦០ |
| | មន្ត្រីក្រសួងបរិស្ថាន (២នាក់) | ២/៣ថ្ងៃ/ខែ | ១/៣០ | ២១៦០ |
| | មន្ត្រីក្រសួងឧស្សាហកម្ម (២នាក់) | ២/៣ថ្ងៃ/ខែ | ១/៣០ | ២១៦០ |
| | **សរុប(២)** | | | **១០.៣២០** |
| ពង្រឹងសមត្ថភាព | បុគ្គលិកក្រុមហ៊ុន Delcom (Kampuchea) PTE.LTD. (ជំនាញបរិស្ថានម្នាក់) | ១/៣ថ្ងៃ/៦ខែ | ៥០០/ថ្ងៃ | ៣.០០០ |
| | **សរុប(៣)** | | | **៣.០០០** |
| គំរោងថវិការ សម្រាប់ជួសជុល ការខូចខាត បរិស្ថាន | ការលុបរណ្តៅ (ដុល្លា/ម៉ែ$^{៣}$) (ក្នុងអាយុកាលនៃការធ្វើអាជីវកម្ម) - ៤០០០០០ម៉ែ$^{៣}$ | | ១,២០/ម៉ែ$^{៣}$ | ៤៨០០០០ |
| | ការដាំឈើឡើងវិញ (ដុល្លា/ហិកតា) នៅក្នុងអាយុកាលនៃការធ្វើអាជីវកម្ម | ០២ហិកតា | ១០០០០/ហត | ២០០០០ |
| | **សរុប(៤)** | | | **៥០០.០០០** |
| គំរោងថវិការសំរាប់វិធានការណ៍កាត់បន្ថយ | ឧបត្ថម្ភដល់អ្នករងគ្រោះ (បុគ្គលិកកម្មករ) និងប្រជាជនក្នុងសហគមន៍ ដែលរងគ្រោះដោយឧបទ្ទវហេតុ ដោយសារសកម្មភាពរបស់គំរោង | | | តាមការជាក់ស្តែង |
| | **សរុបរួម : (១)+(២)+ (៣)+ (៤)=** | | | **៨២៩.៤២០** |

Green Consultancy Firm
KINGDOM OF CAMBODIA

**១៦៨.** អ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator - LEC) នឹងត្រូវតាមដានត្រួតពិនិត្យនូវហេតុប៉ះពាល់ ដូចមានបង្ហាញជូនក្នុងតារាង ៧-១ នៅក្នុងអាយុកាលនៃប្រតិបត្តិការអាជីវកម្មរ៉ែ ដើម្បីធានាបានថាដំណើរប្រតិបត្តិនេះបានអនុវត្តទៅតាមលក្ខខ័ណ្ឌរបស់ផែនការគ្រប់គ្រងបរិស្ថាន។ ម្ចាស់គំរោងមិនត្រូវចាប់ផ្តើមដំណើរការគំរោង មុនពេលដែលក្រសួងបរិស្ថានផ្តល់ការអនុម័តជាផ្លូវការអោយដំណើរការគំរោងនោះទេ។

**១៦៩.** ការតាមដានត្រួតពិនិត្យវាយតំលៃគំរោង ត្រូវធ្វើទៅតាមតម្រូវការនៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដូចបានសង្ខេបនៅក្នុងតារាង ៧-៣។ ម្ចាស់គំរោង (LEC) ត្រូវធ្វើសាវនកម្មផ្ទៃក្នុងរៀងរាល់១ខែម្តងទៅលើការអនុវត្តន៍ EMP លើដំណើរការអាជីវកម្មទាំងមូល ក្នុងពេលដែលស្ថាប័នជំនាញ (មន្ត្រីក្រសួងបរិស្ថាន ឧស្សាហកម្ម រ៉ែ និងថាមពល មន្ត្រីសមត្ថកិច្ចស្រុក ខេត្ត) ត្រូវធ្វើសាវនកម្មទៅ លើការអនុវត្តន៍ EMP លើដំណើរការរបស់ប្រព័ន្ធទាំងមូលរៀងរាល់០៣ខែម្តង ដើម្បីកំណត់អំពីកំហុសឆ្គងណាមួយ និងផ្តល់សេចក្តីកែតម្រូវតាមការចាំបាច់។ ស្ថាប័នជំនាញក៏មានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យលើនីតិវិធីប្តឹងតវ៉ា ដើម្បីធានាបានថា ការផ្តល់ប្រាក់ឧបត្ថម្ភចំពោះបុគ្គលិក/កម្មករដែលរងគ្រោះ ទទួលបានការដោះស្រាយត្រឹមត្រូវពីម្ចាស់ក្រុមហ៊ុនឬមួយយ៉ាងណា? ។

**១៧០.** ម្ចាស់ក្រុមហ៊ុននឹងផ្តល់ការបណ្តុះបណ្តាលអំពីបទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន គោលនយោបាយ ផែនការ និងនីតិវិធីនៃការអនុវត្តន៍ និងការត្រួតពិនិត្យតាមដានប្រព័ន្ធធ្វើប្រព្រឹត្តកម្ម ដល់បុគ្គលិក-កម្មកររបស់ខ្លួន។ ជំនាញបរិស្ថានត្រូវរៀបចំសៀវភៅប្រតិបត្តិសង្ខេបដល់អ្នកសម្របសម្រួបបរិស្ថាន របស់ក្រុមហ៊ុន។ លើសពីនេះទៀតអ្នកសំរបសំរួលបរិស្ថានត្រូវត្រួតពិនិត្យវាយតំលៃ ហើយផ្តល់នូវមតិយោបល់ ផ្សេងៗដល់ម្ចាស់ក្រុមហ៊ុន ថាតើអ្នកបច្ចេកទេសបរិស្ថានរបស់ក្រុមហ៊ុន គួរមានសមត្ថភាពកំរិតណាដើម្បីធានា បានដល់ការអនុវត្តន៍ និងការគ្រប់គ្រងការងារទាំងអស់នោះ។

ក្រុមហ៊ុន ខនសាលធីង ហ្វើម Green Consultancy Firm KINGDOM OF CAMBODIA

DELCOM (KAMPUCHEA) PTE. LTD.